គាត់បានផ្ដើមក្នុងការសរសេរសំបុត្ររបស់គាត់ ដោយនិយាយយោងដល់ខ្លួនគាត់ថា ជាបាវបំរើគឺមិនមែនដែលបង្ហាញថា គាត់គិតតែភាពសំខាន់របស់ខ្លួននៅឡើយ ។ នៅក្នុង ខ ៣-១១ លោកប៉ូល បានបង្ហាញពីរបៀប ដែលគាត់គិតដល់អ្នកដទៃមុនពេល ដែលគាត់គិតដល់ខ្លួនគាត់ ។ សេចក្ដីសប្បុរសរបស់គាត់ ដែលសកម្មសំខាន់យកចិត្តទុក

ដាក់ចំពោះអ្នកដទៃ ដោយមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួនមិនដូចជាពុទ្ធសាសនិកជនដែលគិតថា "គ្មានរូប" គឺគ្មានទុក្ខនោះឡើយ ។ លោកប៉ូលថ្លែងអំណរគុណដល់ពួកគេ (៣) ។ គាត់មានសេចក្តីរីករាយណាស់ចំពោះការរួមជាដៃគូរបស់ ពួកគេនៅក្នុងដំណឹងល្អ (៤-៥) ។ ហេតុអីទៅ? មិនមែនដោយសារតែផលប្រយោជន៍ណាមួយ ដែលគាត់បានទទួលនោះឡើយ តែពីព្រោះតែដោយគុណសម្បត្តិ ដែលនឹងកើនឡើងយ៉ាងសម្បើមចំពោះពួកគេ (សូមមើល ៤:១៧) ។ សាវ័កដែលបានសម្រេចនឹងទទួលរងការឈឺចាប់យ៉ាងច្រើន ដោយព្រោះព្រះគ្រីស្ទ មិនបានហាត់សមនូវកិច្ចការរបស់ខ្លួនឡើយ តែបានអបអរសាទរចំពោះអ្វី ដែលពួកគេបានធ្វើទៅវិញ ។ ពួកគេស្ថិតនៅក្នុងចិត្តរបស់គាត់(៧-៨) ។ គាត់អធិស្ឋានសំរាប់ពួកគេឲ្យបានល្អគ្រប់លក្ខណ៍នៅក្នុងព្រះអម្ចាស់ (៩-១០) ។

គាត់មិនគ្រាន់តែខ្វល់ខ្វាយ ចំពោះអ្នកដទៃជាងគិតពីខ្លួនគាត់ប៉ុណ្ណោះទេ លោកប៉ូលគិតគូរពីការរីកចំរើនពីដំណឹងល្អ ច្រើនជាងការគិតពីសេចក្តីសុខរបស់ខ្លួនគាត់ផ្ទាល់ (១២-១៤) ។ ដោយមានឃ្លាមួយយ៉ាងខ្លីគឺថា "អ្វីដែលកើតឡើងចំពោះខ្ញុំ" គាត់បានរំសាយនូវគ្រប់ទាំងសេចក្តី អំនួត និង ក្តីអយុត្តិធម៌ ដែលគាត់ទទួលរងនៅក្នុងគម្ពីរកិច្ចការ ២១-២៨ ។ តើវាផ្ទុយគ្នាយ៉ាងណា ចំពោះសំបុត្ររបស់បេសកជនសម័យនេះ ដែលផ្តោតយកចិត្តទុកដាក់លើតែបេសកជនខ្លួនឯង និង ការលំបាកនៃការ បំរើព្រះដែលត្រូវឃ្លាតឆ្ងាយពីប្រទេសកំណើតរបស់ខ្លួន! លោកប៉ូលរីករាយដែលអ្នកមិនជឿបានឮដំណឹងល្អ (១៣) គាត់សប្បាយរីករាយ ដែលពួកអ្នកជឿបានទទួលការលើកទឹកចិត្ត ឲ្យធ្វើការបំរើព្រះ (១៤) ទោះបីជាមានការបៀតបៀនលើរូបគាត់ផ្ទាល់ដោយព្រោះការដែលគាត់ផ្តល់នូវការលើកទឹកចិត្តដល់ការមានគំនិតជួយជំរុញទាំងអស់នោះ ។

លោកប៉ូល ធ្វើឲ្យគេបានស្គាល់ព្រះគ្រីស្ទជាជាងឲ្យគេស្គាល់ខ្លួនគាត់ (១៥-១៨) ។ លោកប៉ូល មិនអាចយោគយល់ចំពោះការប្រកាស

ដំណឹងល្អក្លែងក្លាយ (សូមមើល កាឡាទី ១:៦-៩) ដោយការស្អប់ ចិត្ត ដោយមិនពិតត្រង់ និងនាំមនុស្សវង្វេង និង ឃ្លាតចាកពីសិរីរុងរឿង ដែលគេគួរថ្វាយសិរីរុងរឿងនោះ ទៅដល់ព្រះគ្រីស្ទ ។ ប៉ុន្តែសន្ទុះចិត្តមិនត្រង់ ដូចជាការមិនគិតពីខ្លួនឯង គឺឲ្យតែបានប្រកាសពីព្រះគ្រីស្ទ ដោយមិនខ្វល់ពីខ្លួនឯងនោះឡើយ ។ ឥរិយាបថនៃការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ជាចរិតលក្ខណៈរបស់គ្រីស្ទបរិស័ទ ដែលកោតខ្លាចព្រះ ដែលធ្វើឲ្យយើងនឹកឃើញដល់លោក យ៉ូហានបាប់ទីស្ទ[៦] ។ តើនឹងមានការរីកចំរើនប៉ុណ្ណាទៅ ក្នុងព័ន្ធកិច្ចផ្នែកគ្រីស្ទបរិស័ទ បើសិនព័ន្ធការីទាំងអស់មិនបាននឹកដល់ការលើកតម្កើងខ្លួនឯង និង រំលឹកឲ្យដឹងខ្លួនឡើងវិញ ដែលថា ពួកគេគឺជា "ភាជនៈដី . . . ជាអ្នកបំរើដែលអ្នកដទៃអាចទទួលជឿតែប៉ុណ្ណោះ"[៧] ។

ទីបំផុត ពួកសាវ័ក(គ្រីស្ទទូត)ស្ម័គ្រចិត្តលះបង់ចោល នូវភាពស្រណុកសុខស្រួលរបស់ខ្លួន ដើម្បីឲ្យអ្នកដទៃបានរីកចំរើនឡើង (ខ១៨ ចុងខ-ខ២៥) ។ បំណងប្រាថ្នារបស់គាត់ គឺមិនមែនសំរាប់រកការចំណេញផ្ទាល់ខ្លួន ឬ សេចក្ដីសុខផ្ទាល់ខ្លួននោះឡើយ ប៉ុន្តែធ្វើឡើងសំរាប់លើកសិរីល្អរបស់ព្រះគ្រីស្ទ (២១) ។ គាត់ដឹងថា ការស្លាប់នោះគឺជាការចំណេញដោយ សារការដោះលែងគាត់ឲ្យរួចពី "រង្វង់ចាក់ស្រេះលើគ្នានៃសេចក្ដីស្លាប់នេះ" ដើម្បីទទួលនូវសិរីរុងរឿងនៃនគរស្ថានសួគ៌វិញ ។ ប៉ុន្តែនៅក្នុងពេលជាមួយគ្នានេះដែរ គាត់បានដឹងដែរថា បន្តព័ន្ធកិច្ចនៅលើផែនដីនេះនឹងបង្ហាញភ័ស្តុតាង នៃការលើកទឹកចិត្តដល់គ្រីស្ទបរិស័ទ

---

*[៦] យ៉ូហាន ៣:៣០–"ព្រះអង្គនេះបានចំរើនឡើងហើយ ខ្ញុំត្រូវថយវិញចុះ" ។*

*[៧] ២ កូរិនថូស ៤:៧; ១កូរិនថូស ៣:៥ ។ នៅកន្លែងដទៃ លោកប៉ុលព្រមានដល់អ្នកដឹកនាំក្រុមជំនុំដែល "បំភ្លៃសេចក្ដីពិត ដើម្បីកៀរប្រមូលសិស្សឲ្យមកតាមគេឲ្យបានច្រើន" (កិច្ចការ ២០:៣០) ។ តែផ្ទុយទៅវិញសូមមើល អត្តចរិតរបស់ឌីអូត្រេព នៅក្នុងសំបុត្រ យ៉ូហានទី៣ ៩-១០ ។*

ក្មេងៗនិងមានជំហរ មុតមាំថា ព្រះជាម្ចាស់នឹងទុកឲ្យគាត់ស្នាក់នៅជាមួយនឹងពួកគេ ។ ការនេះនឹងគួសបង្ហាញពីភាពចំរើនជឿនលឿនយ៉ាងសម្បើមរបស់គ្រីស្តបរិស័ទភាគច្រើន ដែលពួកគេអាចបញ្ជាក់យ៉ាងស្មោះត្រង់ថា "ខ្ញុំគាប់ចិត្តចង់បានឲ្យស្ថានសួគ៌ និង ព្រះគ្រីស្តបន្តជីវិតនៅលើផែនដី ។" ប៉ុន្តែលោក ប៉ូល បានគិតហួសពីចំណុចទៅទៀតគឺគាត់អាចនិយាយថា "ទោះបីជាស្ថានសួគ៌ ប្រសើរគ្រាន់បើសំរាប់ខ្ញុំមែន ការស្នាក់នៅរបស់ខ្ញុំនៅទីនេះនៅលើផែនដី គឺប្រសើរសំរាប់អ្នករាល់គ្នា ។ ហេតុដូច្នេះហើយខ្ញុំទុកចិត្តដល់ព្រះជាម្ចាស់ នឹងទុកឲ្យខ្ញុំនៅទីនេះក្នុងពេលឥឡូវនេះ" ។

ដូច្នេះ នៅក្នុងខគម្ពីរបើកឆាកនៃជំពូកនេះ យើងបានឮពីសេចក្តីអំណាររបស់លោក ប៉ូល និង ចាប់ផ្តើមឃើញពីរបៀបដែលក្តីអំណារនេះផុសចេញ ពីភាពមិនអាត្មានិយមរបស់គាត់ គាត់បង្ហាញពីភាពមិនអាត្មានិយម សូម្បីតែនៅពេលដែលមានភាពលំបាកយ៉ាប់យឺន ។ បន្ទាប់មកនៅខ២៧-៣០ គាត់បានបោយដៃហៅអ្នកអានរបស់គាត់ឲ្យរស់នៅក្នុងជីវិតដែលស្រដៀងគ្នានោះដែរ ។

ដំបូងគាត់បានជំរុញ ឲ្យគេរស់នៅក្នុងចរិតលក្ខណៈ ដែលមិនគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ដោយធ្វើខ្លួនឲ្យ "សមនឹងតម្លៃនៃដំណឹងល្អរបស់ព្រះគ្រីស្ត" (២៧) ។ នៅពេលយើងធ្លាក់ខ្លួនក្នុងការលោភលន់ស្រើបស្រាល ឬ ខ្ជិលច្រអូស គឺពីព្រោះតែដោយសារយើងគិតពីខ្លួនយើង មិនគិតដល់ព្រះគ្រីស្ត ដល់អ្នកដទៃ ឬ ដល់ការទទួលខុសត្រូវរបស់យើង ។ ទីពីរ គាត់បានជំរុញឲ្យគេរស់នៅក្នុងភាពមួយដែលមិនគិតតែវិញ្ញាណតែមួយ" និង ស្កប់ស្កល់ចិត្ត "ជាមនុស្សតែមួយ" (២៧) ។ នៅពេលមានការបាក់បែក និង មានស្មារតីនៃការប្រកាន់បក្សពួក គឺពីព្រោះតែមកពីយើងឲ្យតម្លៃរបស់យើងខ្ពស់ជាងព្រះគ្រីស្ត ឬ ខ្ពស់ជាងពួកជំនុំទាំងមូល ។ ទីបី គាត់បានជំរុញឲ្យគាត់រស់នៅ ដោយមិនគិតពីភាពអាត្មា

និយម ដោយមានសេចក្តីក្លាហាន នៅចំពោះមុខសេចក្តីរងការឈឺចាប់ ។ នៅពេលយើងរួញក្រញ៉េន នៅចំពោះមុខនៃការប្រឆាំងជំទាស់ ឬ ព្រមចុះចាញ់ដល់ការនោះឯង គឺពីព្រោះតែយើងគិតពីសេចក្តីសុខស្រួលរបស់យើងផ្ទាល់ជាជាងដល់សេចក្តីពិតរបស់ព្រះជាម្ចាស់ ។ បើសិនជាយើងធ្វើតាមចំណុចទាំងបីនេះយើងនឹងបានរួមចំណែកក្នុងការរំលែកអំណាររបស់ពួកសាវ័ក នៅពេលយើងមានភាពជាអ្នកមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន (អត្តទត្ថបុគ្គល)ទោះបីជាមានភាពលំបាកលំបិនយ៉ាងណាក៏ដោយ ។

## ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គឺជាគន្លឹះនៃការទទួលជោគជ័យ២:១-៣០

កាលពីប្រាំសតវត្សរ៍ កន្លងមកហើយលោក គ្រីស្តូហ្វ កូឡុម បានប្រថុយ ដោយមិនខ្លាចធ្វើដំណើរតាមសំពៅទៅទិសខាងលិច ដោយប៉ុនប៉ងទៅឲ្យដល់ភូមិភាគចុងបូព៌ា ។ ពីព្រោះការសិក្សារបស់ គ្រីស្តូហ្វ កូឡុម ស្តីពីផែនដី បានបង្ហាញឲ្យដឹងថា ផែនដីរាងមូលដូចបាល់ មិនមែនសំប៉ែតទេ គម្រោងផែនការរបស់គាត់បានសម្រេចមែន ។ បើអាមេរិកមិនបានជួយធ្វើអន្តរាគមន៍ទេនោះ ការនោះប្រហែលជាទទួលបានជោគជ័យបាត់ទៅហើយ ។

ការមាននិមិត្ត(ចក្ខុវិស័យ)នៃភាពប្រាកដនិយម ដែលពឹងលើការមិនស្តាប់តាម សមត្ថភាពផ្នែកសតិបញ្ញា ជាទូទៅផ្តល់ផលប្រយោជន៍ដល់អស់អ្នកណា ដែលព្រមដកថយមកសញ្ជឹងគិតមើលពីរូបភាពនៃហេតុការណ៍នោះ ។ ការមាននិមិត្ត ដោយឈរលើការពិចារណាថ្លឹងថ្លែងនេះឯងតែងតែនៅ ពេលចុងក្រោយទទួលបាននូវ ភាពប្រាកដនិយមច្រើនជាង មិនថាឡើយពួកគេចាំបាច់ត្រូវជាប់ជំពាក់ លើទ្រឹស្តីដែលថា ផែនដីមូលជាជាង ផែនដីរាងសំប៉ែត រូបវិទ្យាបែប អេនស្តេននិយម ជាជាង

រូបវិទ្យាបែបពុត្ធិនិយម ឬ ភាពមិនអាត្មានិយម ជាជាងភាពអាត្មានិយម ដូចជាគន្លឹះនាំឲ្យមាន អំណារ ។

តាមពិតទៅ ការគិតឃើញភ្លាម និង មិនបានសញ្ជឹងគិតនោះ បានផ្តល់ជាការណែនាំ របៀបដែលបុគ្គលអាត្មានិយមណាម្នាក់សម្រេចបានជោគជ័យ និង អំណារនោះឯង នាំមកសំរាប់តែអាត្មានិយម ដើម្បីស្វែងរក ដោយគ្មានការសុំអភ័យទោស ឬ ការកែប្រែ ការទទួលស្គាល់របស់ខ្លួន ភាពរីកចំរើន ការចម្រុងចម្រើន និង សន្តិសុខរបស់ខ្លួន ។ មានអ្វីកើតឡើងចំពោះអ្នកដទៃ ដែលប្រសើរបំផុតនៃលំដាប់ទីពីរនោះ ។ ប៉ុន្តែ អស់អ្នកណា ដែលព្រមដកថយពីគំនិតចង់បានប្រជាប្រិយភាពភ្លាមៗ និង ការផ្តល់ឲ្យមាននិមិត្ត ដែលមានទស្សនៈនៃការថ្លឹងថ្លែងពីភាពប្រាកដនិយមនោះ គឺជាម្នាក់ដែលបានគិតរាប់បញ្ចូលនៃលទ្ធផលនៃព្រះគម្ពីរនោះ បានរកឃើញភាពផ្ទុយគ្នាពិតប្រាកដជាង ។ មធ្យោបាយដើម្បីឲ្យសម្រេចបានជោគជ័យ គឺត្រូវគិតដល់អ្នកដទៃជាមុន ។

នៅក្នុងភីលីព ជំពូក ២ បង្រៀនពីសេចក្តីពិតនេះ ដោយទីមួយបង្ហាញពីភាពមិនអាត្មានិយម (ដែលបានរៀបរាប់ពីចំណុចអវិជ្ជមាន) ឬ ដោយគិតពីប្រយោជន៍អ្នកដទៃជាមុន (បានបញ្ជាក់ពីចំណុចវិជ្ជមាន) នៅក្នុងខ ១-៤ (ជាពិសេស ខ ៣-៤) ។ ផ្នែកកណ្តាលនៃ ខ ១២-១៨ បានពន្យល់យ៉ាងល្អិតល្អន់នៃផ្ទៃរឿង ដោយការជំរុញឲ្យមាន កាស្តាប់បង្គាប់ដ៏ប្រសើរ (ជាជាងបំណងប្រាថ្នារបស់ខ្លួនឯង) និង ការច្រានចោលនៃការរអ៊ូរទាំ (អំពើប្រព្រឹត្តខុសចំពោះខ្លួនឯង) និង ការឈ្លោះប្រកែក ដោយព្រោះតែ (តាមគំនិតផ្ទាល់ខ្លួន) ។

គំរូនៃឧទាហរណ៍ផ្ទាល់របស់លោក ប៉ូល ស្តីពីអំណារ ដែលបានរាំងស្ទះពីការហូរចុះពីខ្លួនរបស់គាត់ ចាក់ស្រោចទៅដល់អ្នកដទៃ បានសារុបសេចក្តីមកក្នុងផ្នែកដ៏តូចនេះឯង ។ ជំពូកដែលនៅសល់ពីនេះ មាន

ផ្លូវបី ដែលនាំឲ្យមានជោគជ័យ ដែលបានគូសបញ្ជាក់នៅក្នុងជីវិតរស់នៅរបស់បុគ្គលបីរូប ។

បុគ្គលទីមួយ នៅក្នុងចំណោមបុគ្គលទាំងនេះ គឺព្រះគ្រីស្ទ និងមានភាពមិនគិតពីប្រយោជន៍អាត្មានិយមហួសពីការស្មាន លោក ប៉ូល បានលើកបញ្ជាក់ នៅក្នុងជីវិតរស់នៅរបស់មនុស្ស ដែលបានចែងថា មនុស្សដែលមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ចូរបន្ទាបខ្លួនចុះ ដើម្បីឲ្យមានពេលមួយព្រះជាម្ចាស់អាចលើកដំកើងអ្នកនោះឡើងវិញ ។

ពួកទេវវិទូជាច្រើនរបស់ព្រះគម្ពីរ ជាទូទៅបានលើកយក ខគម្ពីរ ភីលីព ២:៥-៩ នៅពេលដែលគេស្វែងយល់ពី **Kenōsis** ឬការលះចោលសិរីល្អរបស់ព្រះគ្រីស្ទ "ដែលព្រះអង្គដាក់រាជអំណាចរបស់ទ្រង់ចោលទាំងអស់" (ខ ៧) ។ ប៉ុន្តែលោក ប៉ូល បានលើកយក (ខ ៦-១១) មកនិយាយ គឺមិនមែនធ្វើឲ្យមានឧបសគ្គ នៃការបកស្រាយផ្នែកទេវសាស្ត្រឡើយ ប៉ុន្តែដើម្បីផ្តល់ជាគំរូនៃការអនុវត្តន៍ជាក់ស្តែងមួយ សំរាប់ឲ្យគ្រីស្ទបរិស័ទទាំងអស់ធ្វើតាម ។ លោកគ្រីស្តទូតមានប្រសាសន៍ថា ឥរិយាបថរបស់យើងគួរតែធ្វើតាមព្រះគ្រីស្ទ ។ និយាយឲ្យងាយស្តាប់ទៅ ព្រះគ្រីស្ទមានតួនាទីខ្ពង់ខ្ពស់ ("គឺស្មើនឹងព្រះជាម្ចាស់")[៨] និង ព្រះអង្គយាងចុះមកនៅក្នុងសណ្ឋានទាបបំផុត ("សុគតនៅលើឈើឆ្កាង") ។ ព្រះអង្គមិនបានសំចៃទុក ឋានៈជាព្រះរបស់ព្រះអង្គអ្វីបន្តិចឡើយ តែព្រះអង្គបានលះចោលឋានៈនេះ ដើម្បីក្លាយមកជាអ្នកបំរើ សំរាប់ការល្អរបស់យើង ។ លោក ប៉ូល បាន និយាយថា យើងគួរតែធ្វើដូចគ្នានោះដែរ ។ ដោយ

---

(8) This accurately translates the phrase ἐν μορφῇ θεοῦ ὑπάρχων. Μορφῇ denotes an outward manifestation that accurately reflects something's inner essence, in contrast to σχῆμα, which refers to an outward appearance that may only be temporary. This is therefore a strong statement for the deity of Christ.

ហេតុតែព្រះយេស៊ូវ ព្រមបន្ទាបអង្គទ្រង់ដល់ក៏រិត ទើបព្រះជាម្ចាស់បាន លើកព្រះអង្គឡើងដល់ក៏រិតខ្ពស់ ។ ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គឺជាគន្លឹះនាំឲ្យបានទទួលជោគជ័យ និង ទទួលបាននូវអំណរ វាហាក់បី ដូចជាផ្ទុយពីសតិបញ្ញាពេកហើយទេដឹង ប៉ុន្តែព្រះគ្រីស្ទបានបង្ហាញថា គឺជាការពិត ។ មនុស្សដែលមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន ព្រមបន្ទាបខ្លួន ដើម្បីឲ្យមានពេលមួយ ព្រះជាម្ចាស់អាចលើកគាត់ឡើង ។ ឬក៏ដូចដែល ព្រះគ្រីស្ទបង្រៀន "អស់អ្នកណាតម្កើងខ្លួន នឹងត្រូវបន្ទាបចុះ និង អស់ អ្នកណា ដែលបន្ទាបខ្លួន នឹងត្រូវតម្កើងឡើងវិញ ។"[៩]

បុគ្គលទី ២ គឺ ធីម៉ូថេ ដែលមានជីវិតរស់នៅបង្ហាញថា ជាមនុស្ស ដែលចាប់យកកន្លែងលេខ ២ ដើម្បីនៅពេលមួយគាត់អាចសប្បាយរីក រាយនៅកន្លែងលេខ ១ បាន ។ ធីម៉ូថេ សន្មត់ថា កន្លែងលេខ ២ នោះគឺ ទំនាក់ទំនងរបស់គាត់ ជាមួយនឹងពួកជំនុំក្រុង ភីលីព គាត់មិនខំស្វែងរក លាភសក្ការៈ សំរាប់បំពេញប្រយោជន៍ផ្ទាល់ខ្លួនឡើយ មិនដូចអ្នកដទៃ ដែលគេកំពុងធ្វើនោះឡើយ (២០-២១) ។ គាត់សន្មត់ថា កន្លែងទី ២ របស់គាត់ នោះគឺទំនាក់ទំនងរបស់គាត់ ជាមួយលោក ប៉ូល គឺគាត់បំរើ ប្រៀបដូចជាកូនប្រុស និង ឪពុក (២២) ។ ហេតុផលនោះគឺថា ធីម៉ូថេ គឺជាម្នាក់ ដែលបញ្ជូនទៅបំពេញបេសកកម្មដ៏សំខាន់នេះ នៅឯក្រុង ភីលីព (១៩.២៣) ។ ដោយការបំរើដោយស្មោះ និង ដោយពិតត្រង់ ជាអ្នក លេខ ២ ធីម៉ូថេ ក្លាយទៅជាមនុស្សលេខ ១ នៅក្នុងក្រសែភ្នែករបស់ លោក ប៉ូល (២០. "ខ្ញុំមិនមាននរណាមួយទៀតដូចជាគាត់ឡើយ") ។ "អ្នកដឹកនាំ" ជាច្រើនទូទាំងប្រវត្តិសាស្ត្រក្រុមជំនុំ តែងតែទទូចសុំឲ្យ ឈ្មោះ និង ការងាររបស់គេលើកឡើងខ្ពស់ជាងគេទាំងអស់ ។

---

[៩] *ម៉ាថាយ ២៣:១២; លូកា ១៤:១១; ១៨:១៤ ។*

បុគ្គលទី ៣ គឺ អេប៉ាប្រូឌីត ។ យើងបានដឹងថា នៅក្នុងជីវិតរស់នៅរបស់គាត់គឺថា គាត់ជាមនុស្សមិនគិតពីអាត្មានិយម គឺគិតដល់ការឈឺចាប់របស់អ្នកដទៃ ដូច្នេះនៅពេលមួយអ្នកដទៃទទួលគាត់ដោយអំណរ ។ ជារឿយៗនៅពេលដែលមនុស្សឈឺ គឺគេក្លាយជាអ្នក ដែលគិតពីអាត្មានិយម ។ ជាពិសេសគេចង់ឲ្យអ្នកដទៃគោរព និង បំរើគេ ពីព្រោះគេមិនស្ងួវស្រួលខ្លួន ។ បើសិនការយកចិត្តទុកដាក់នោះ បានទទួលមកមិនដូចការរំពឹងទុកនោះ មនុស្សបែបហ្នឹង អាចខឹង និង មួម៉ៅ ។ ប៉ុន្តែចូរមើលពីភាពមិនគិតពីប្រយោជន៍អាត្មានិយម របស់បុរសនេះ ។ ដំបូងគាត់ខំបំរើលោក ប៉ូល ទាល់តែបាក់កម្លាំងកាយ និង កម្លាំងចិត្ត ។ ទីពីរ នៅពេលដែលគាត់ធ្លាក់ខ្លួនឈឺជិតស្លាប់ គាត់ចាប់ក្លាយទៅជាបាក់ទឹកចិត្ត ពីព្រោះគាត់សោកស្តាយខ្លាចក្រែងអ្នកដទៃ ទទួលរងគ្រោះដោយសារជម្ងឺរបស់គាត់ ។ នេះនែ គឺជាមនុស្សដែលគិតពី ទុក្ខលំបាករបស់អ្នកដទៃ គឺថា "ខ្ញុំឈឺ និង ខ្ញុំសោកស្តាយចំពោះ ប្រយោជន៍របស់អ្នករាល់គ្នា !" ។ ហេតុផលនោះគឺថា លោក ប៉ូល បាន ផ្តល់នូវការណែនាំដល់ពួកក្រុងភីលីព ឲ្យ "ស្វាគមន៍របស់គាត់នៅក្នុងព្រះនាមព្រះជាម្ចាស់ ដោយអំណរយ៉ាងសម្បើម" (២៩) ។

ហេតុដូច្នេះហើយដោយសារគោលគំនិត និងគំរូរបស់ភីលីព ជំពូក ២ បង្រៀនយើងថា គន្លឹះនៃការទទួលជោគជ័យនៅក្នុងព្រះនេត្រ របស់ព្រះជាម្ចាស់ហើយនិងក្នុងអំណរ ដែលចេញជាលទ្ធផលមកគឺការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួនតែការខំធ្វើសំរាប់ជាប្រយោជន៍ដល់អ្នកដទៃ ។

## ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គឺមានន័យថា មើលរំលង ប្រយោជន៍របស់យើងផ្ទាល់ ៣:១-១១

អ្នកនិពន្ធជនជាតិអាមេរិកឈ្មោះ ណាថាណែល ហស៊ីន បានសរសេររឿងខ្លីមួយមានចំណងជើងថា "មុខធំលើជញ្ជាំងភ្នំ" (The Great

Stone Face) ដែលស្តីពីក្មេងប្រុសម្នាក់បានចំណាយពេលវេលា សញ្ជឹងគិតអំពីថ្មផ្តុំចូលគ្នា បង្កើតបានជាមុខមនុស្សដ៏ស្រស់ស្អាតស្ថិតនៅយ៉ាងខ្ពស់នៅក្នុងចម្រាក់ភ្នំ ដែលនៅក្បែរខាងគ្នានោះឯង ។ រឿងព្រេងនិទាននោះឯងបានទស្សន៍ទាយថានៅថ្ងៃណាមួយ មនុស្សពិតជានឹងកើតឡើងក្លាយជាមនុស្សដែលមានទឹកមុខនិងចរិតលក្ខណៈឆ្លុះឲ្យឃើញពីរូបភាពដ៏ប្រណិត ។ ចៅមាណពនោះខកចិត្តយ៉ាងខ្លាំងដោយមានបេក្ខជនផ្សេងៗជាច្រើនមិនបានសម្រេចតាមទំនាយនោះ ។ បន្ទាប់មក មានថ្ងៃមួយសហគមន៍បានទទួលស្គាល់ថា អឺណេាស ដែលឥឡូវនេះចំរើនវ័យជាអ្នកដឹកនាំវាងវៃ សប្បុរស អាចទទួលយកធ្វើជារូបនៃ "មុខធំលើជញ្ជាំងភ្នំ" នេះ ។ ហេតុដូច្នេះលោក ហាកស៊ន បានបញ្ជាក់ថា ផ្នែកចិត្តសាស្ត្របានបង្រៀនយើងថា យើងក្លាយទៅជាមនុស្សបែបណានោះគឺវា អាស្រ័យលើការអ្វីដែលយើងសម្លឹងមើល ហើយប្រកាន់យកនោះឯង ។

បើសិនជាដូច្នេះមែន អ៊ីចឹងយើងជាគ្រីស្តបរិស័ទ យើងគួរតែសម្លឹងមើលទៅព្រះគ្រីស្ត ប្រសើរជាងមើលមកខ្លួនឯង ។ មានមធ្យោបាយ ៣ យ៉ាង ដែលយើងអាចធ្វើការនោះ ។

## ទីមួយ យើងអាចសម្លឹងមើលទៅឯព្រះគ្រីស្ត ដោយក្តីអំណរនៅក្នុង ព្រះអម្ចាស់ (៣:១)

នេះជាបំណងព្រះហឫទ័យ ជាទូទៅរបស់ព្រះជាម្ចាស់សម្រាប់យើង[១០] ។ គឺជាជំនឿ ទោះបីជាជីវិតរស់នៅមិនបានប្រព្រឹត្តទៅដោយមានការល្អប្រសើរក៏ដោយ[១១] ។ បុគ្គល ដែលគិតតែពីប្រយោជន៍ផ្ទាល់

---

[១០] ខ. *ទំនុកតម្កើង ១០០ និង ១ថែស្សាឡូនិក ៥:១៦-៨*

[១១] ខ. *ហាបាគូក ៣:១៧-១៨*

ខ្លួន គិតតែពីអាត្មាអញ្ញរហូត គឺគិតពីសុខមាលភាពរបស់ខ្លួន ឋានៈរបស់ខ្លួន ការទទួលស្គាល់ពីអ្នកដទៃរបស់ខ្លួន ។ បុគ្គល ដែលមិនគិតតែពីអាត្មានិយម គឺសម្លឹងរំលងពីប្រយោជន៍ផ្ទាល់ខ្លួន និង គិតតែពីការប្រកបជិតស្និទចំពោះគ្រីស្ទបរិស័ទ និង ដោយមានជំនឿនៅក្នុងព្រះអម្ចាស់ដោយអំណរ ។

## ទីពីរ យើងអាចសម្លឹងមើលទៅព្រះគ្រីស្ទ ដោយការបដិសេធចោលអ្នកទាំងឡាយណា ដែលគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន (៣:២-៣)

បទគម្ពីរអង់គ្លេស (NIV) គួរឲ្យស្តាយដែលបាត់ពាក្យ បីម៉ាត់ដែលគេពោលដដែល "ចូរប្រយ័ត្ន !" នៅក្នុង៣:២[១២] ។ ពាក្យទាំងនោះដែលប្រឆាំងនឹងពួកគ្រីស្ទទូត ហេតុដូច្នេះពួកគ្រីស្ទទូតព្រមានយ៉ាងខ្លាំងក្លាដល់អ្នកដែលកាន់សាសនា ដែលសង្កត់ធ្ងន់លើការកាត់ស្បែកខ្លាំងជាងគិតដល់ព្រះគ្រីស្ទ គឺមានន័យថាគេជាអ្នកខំធ្វើខ្លួនឯងជាជាងពឹងព្រះជាម្ចាស់ឲ្យធ្វើសំរាប់គេ ។ គេរីករាយសាទរចំពោះខ្លួនឯង ។ នេះគឺជាការខុសឆ្គងដ៏ធ្ងន់ធ្ងរបំផុត ។ ចំពោះអ្នកណា ដែលគិតបែបនោះគឺជា "ពួកឆ្កែ"[១៣] "មនុស្សដែលប្រព្រឹត្តការអាក្រក់" "ពួកអារសាច់" ។ ព្រះគម្ពីរ

---

[១២] *ការនេះបង្ហាញពីរូបសញ្ញានៃសុន្ទរកថា ដែលគេឲ្យឈ្មោះ "anaphora" ដែលប្រើពាក្យដដែលៗ នៅពេលចាប់ផ្តើមនៃប្រយោគបន្តគ្នា សម្រាប់ការសង្កត់ធ្ងន់លើអត្ថន័យទាំងនោះ ។*

[១៣] *នៅក្នុងចំណោមសាសនាយូដា កាលពីសម័យដើមក្នុងព្រះគម្ពីរសត្វឆ្កែ គឺជា "សត្វគួរឲ្យស្អប់ សត្វឥតប្រយោជន៍ និង ជាសត្វរហែមរហាមបំផុត" ។ គឺជាសត្វព្រៃពាក់កណ្តាល ស្រុកពាក់កណ្តាល ដែលរស់នៅមានមុខងារដូចជាសត្វស្វាន នៅតាមគំនរសម្រាម ។ ចំពោះយេសេបិល ដែលសត្វឆ្កែហែកស៊ី គឺជាការអាម៉ាស់បំផុតសម្រាប់នាង ។ នៅពេលដែលព្រះបាទដាវីឌ បានហៅខ្លួនឯង*

ផ្ដោតចំពោះព្រះគ្រីស្ទគឺថា "ជាទីបន្ទាល់នៃព្រះយេស៊ូ គឺជាវិញ្ញាណនៃការប្រាប់ពីទំនាយ ហើយយើងក៏ត្រូវតែគិតដូច្នេះដែរ ។ យើងមិនហ៊ានផ្ដោតសំខាន់លើខ្លួនយើងឡើយ ។ លោក ប៉ូល និយាយដោយឥតសង្ស័យថា "ចូរឲ្យយើងអរសប្បាយនៅក្នុងព្រះអម្ចាស់ ! ហើយចូរប្រយ័ត្នចំពោះអស់អ្នកដែលសប្បាយរីករាយនៅក្នុងតែខ្លួនឯងនោះ !" ។

## វិធី យើងត្រូវផ្ដោតផ្នែកសម្លឹងទៅឯព្រះគ្រីស្ទ និង សូមបំភ្លេច ចោលនូវ ការសម្រេចជោគជ័យផ្ទាល់ខ្លួន (៣:៤-១១)

គឺគ្មានអ្វីខុសឆ្គងទេ ចំពោះការដែលយើងសម្រេចបាន ដូចជាផ្នែកសាសនា ផ្នែកសីលធម៌ សម្រេចបានផ្នែកសិក្សាធិការ ផ្នែកសង្គម ឬក៏អ្វីក៏ដោយ ។ ប៉ុន្តែមានការខុសឆ្គងយ៉ាងធំធេងបំផុតដោយយើងទុកចិត្តលើការ ដែលយើងសម្រេចបាននោះខ្លាំងពេកឬក៏អួតចំពោះការនោះ ។ លោក ប៉ូល បានទទួលជោគជ័យសម្រេចបាននូវអ្វីៗជាច្រើន នៅក្នុងលទ្ធិសាសនាយូដា កាលពីសម័យគាត់រស់នៅនោះ (៣:៤-៦) ។ ប៉ុន្តែតើគាត់ទុកចិត្ត យ៉ាងខ្លាំងលើការទាំងអស់នោះ ឬ មានអំនួតលើការអស់ទាំង

---

*ថាជា ឆ្កែឆ្មាប់ នោះព្រោះទ្រង់ចង់បន្ទាបខ្លួនឲ្យថោកមែនទែន ។ នៅពេលដែលសុភាសិតប្រៀបធៀបមនុស្សល្ងីល្ងើទៅនឹង សត្វឆ្កែ ដែលវិលមកពីស៊ីកំអួតរបស់ខ្លួន សាឡូម៉ូនចង់បង្ហាញពីភាពល្ងង់ល្ងើរបស់មនុស្សខ្លៅនោះឯង ។ ម្ចាស់ដែលចិញ្ចឹមវា តែងគិតថា សត្វឆ្កែ ជាសត្វគួរឲ្យស្រឡាញ់ គួរឲ្យចង់ឱបរឹតវា និង គួរឲ្យរាក់ទាក់ គឺថា ឆ្កែ អាចទៅជាអ៊ីចឹងមែន ។ ប៉ុន្តែកាលពីសម័យព្រះគម្ពីរហៅនរណាម្នាក់ថា អាឆ្កែ នោះគឺជាការ ដែលមិនអាចទទួលបានឡើយ វាទៅជាបន្ទុះបង្អាប់យ៉ាងខ្លាំង ។ ដូច្នេះគ្មានអ្វីប្លែកនៅចុងបញ្ចប់នៃសម័យព្រះគម្ពីរ យើងប្រទះឃើញថា នៅខាងក្រៅនៃទីក្រុងយេរូសាឡិមថ្មី គឺមានពួកឆ្កែ ។ នេះឯងហើយដែលលោក ប៉ូល គិតដល់ពួកមនុស្សទាំងនេះ ។*

នោះទេ? តើគាត់ពិចារណាមើលពីក្រដាសស្នាមដែលបញ្ជាក់ពីសមត្ថភាពរបស់មនុស្សដូចម្ដេចទៅ ? របស់ទាំងអស់នោះ ខាតទទេគឺជារបស់ឥតប្រយោជន៍ (ជាសម្រាម)[១៨] ។ មនុស្សដែលគិតតែពីប្រយោជន៍ខ្លួនឯង គិតតែពីពូជអម្បូរណ៍ និង ការទទួលបានជោគជ័យរបស់ខ្លួន ។ គ្រីស្ទបរិស័ទ ដែលមិនបានគិតពីប្រយោជន៍ផ្ទាល់ខ្លួនពេញចិត្តនឹងសម្លឹងទៅឯព្រះគ្រីស្ទវិញ។

សូមបញ្ជាក់ម្ដងទៀត ហេតុផលនៃការដែលបែរចេញពីការយកចិត្តទុកដាក់លើខ្លួនឯងគឺមិនមែនដោយសារថា ការសម្រេចទទួលបានជោគជ័យរបស់មនុស្ស គឺអត់ប្រយោជន៍នោះទេ ប៉ុន្តែអ្វីដែលគេបានទទួលនៅក្នុងព្រះគ្រីស្ទនោះគឺ សំខាន់ជាង ។ លោក ប៉ូល បានជួបប្រទះយ៉ាងហោចណាស់ក៏ចំណុចទាំងនេះដែរគឺ ១)ចំណោញក្នុងព្រះគ្រីស្ទ ២)បានរកឃើញនៅក្នុងព្រះគ្រីស្ទ ៣)ទទួលបានសេចក្ដីសុចរិតនៅក្នុងព្រះគ្រីស្ទ ៤)ស្គាល់ព្រះគ្រីស្ទ អំណាចចេស្ដានៃការរស់ឡើងវិញ និង ការរួមចំណែកក្នុងទុក្ខវេទនារបស់ព្រះអង្គ ៥)មានលក្ខណៈដូច ជាព្រះគ្រីស្ទ

---

[១៨] *មានន័យថា "លាមកសត្វ កកជ្រាំ ចំណីអាហារដែលផ្អូមជាដើម ។" ពាក្យនេះគេប្រើដើម្បីបញ្ជាក់ពីការគួរឲ្យអាណិត និង គួរឲ្យក្អេះខ្ពើម ដូចជាខ្មោចដែលត្រីចឹកស៊ីអស់ពាក់កណ្ដាលហើយនោះ ។ ហេតុដូច្នេះហើយលោក ប៉ូល បញ្ជាក់យ៉ាងច្បាស់នៃការបង្អាប់ដល់គុណសម្បត្តិរបស់គាត់ផ្ទាល់ ដោយការធ្វើការប្រៀបធៀបជាមួយនឹងព្រះគ្រីស្ទ ។* **J. I. Packer** *និយាយត្រង់ៗ នៅក្នុងការសង្កេតមើលរបស់គាត់ថា "នៅពេលដែលលោក ប៉ូល និយាយថា គាត់រាប់ពីកិច្ចការ ដែលគាត់ធ្លាប់មានគឺ "ឥតប្រយោជន៍ទទេ" គាត់មិនមែនមានន័យថា គាត់មិនបានគិតពីរបស់ទាំងនោះថា មានតម្លៃខ្លះៗប៉ុណ្ណោះ តែថែមទាំងគាត់មិនឲ្យរបស់ទៅដាក់ក្នុងគំនិតរបស់គាត់ទៀតផង គឺថា: អ្វីដែលជាមនុស្សធម្មតាចំណាយពេលគិតស្រមោះដល់រឿងឥតប្រយោជន៍ជាជាង ( ការស្គាល់ព្រះជាម្ចាស់ ២១ )។*

និង ៦)បានសម្រេចដល់ការរស់ឡើងពីស្លាប់[១៥] ។ ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គឺមានន័យថា មើលរំលងខ្លួនរបស់យើង គឺសម្លឹងទៅឯព្រះគ្រីស្ទវិញ ដែលនៅក្នុងព្រះអង្គ យើងអាចរកឃើញការអស្ចារ្យច្រើនទៀត ។ ហេតុផលនៃការមិនគិតពីប្រយោជន៍ខ្លួនឯងនោះ ដែលមានផលផ្លែដ៏ល្អ និង អំណរដ៏ប្រសើរ ។

## ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន គឺមានន័យថាធ្វើសម្រាប់ពេលអនាគត ជាជាងធ្វើសម្រាប់ពេលបច្ចុប្បន្ន ៣:១២-៤:១

ការគិតពីប្រយោជន៍ផ្ទាល់ខ្លួន ជារឿយៗសម្លឹងមើលមិនឆ្ងាយ ចង់ឃើញការស្កប់ចិត្តភ្លាមៗ ជាជាងថ្ងៃអនាគត ។ ថ្ងៃស្អែក គឺមិនច្បាស់លាស់ អ្វីដែលយើងមានគឺសំរាប់តែឥឡូវនេះឯង ។ ហេតុដូច្នេះហើយ "ចូរយើង ស៊ី និង ផឹក ព្រោះស្អែកព្រឹកយើងនឹងស្លាប់ ។" តែផ្ទុយទៅវិញ ផ្ទត់គំនិតដែលផ្ទុយពីនេះ ធ្វើឲ្យការព្រមលះបង់ការស្កប់ចិត្ត ពេលបច្ចុប្បន្ន ជួយបង្កើតឲ្យមានអនាគត ។ លោក ប៉ូល លើកទឹកចិត្តដល់គ្រីស្ទបរិស័ទ ដែលរស់នៅសម្រាប់ថ្ងៃអនាគត ។ មិនមែនជារឿង ដែលទាក់ទងនឹងអតីតកាល (៣:១២-១៦) ហើយរស់នៅសម្រាប់អនាគត មិនមែនរស់នៅក្នុងពេលបច្ចុប្បន្ន (៣:១៧-២១) ។ នេះគឺជារបៀប ដែលយើងត្រូវឈររឹងមាំ (៤:១) ។

---

[១៥] *ឃ្លានេះមិនមែនបានន័យថាលោក ប៉ូល សង្ស័យ ឬ ក៏ថាការរស់ឡើងវិញ ឬ ក៏ថាគាត់នឹងរួមចែករំលែកក្នុងការរស់ឡើងវិញនោះ ។ តែផ្ទុយទៅវិញគាត់សង្ឃឹម ដោយសម្ព័ន្ធជាមួយព្រះគ្រីស្ទ ដើម្បីទទួលនូវការប្រទានចេស្តា ក្នុងការរស់នៅរបស់ព្រះគ្រីស្ទនៅលើផែនដីនេះ គឺទទួលនូវបទពិសោធន៍នៃជីវិតរស់នៅជាប្រចាំថ្ងៃរបស់គាត់ គឺមានន័យថាគាត់បានទទួលនូវការរស់ឡើងវិញជាមួយព្រះគ្រីស្ទ ។*

## និមួយ យើងរស់នៅសម្រាប់អនាគត
## មិនមែនសម្រាប់អតីតកាលទេ (៣:១២-១៦)

នៅក្នុងការសម្លឹងមើលឃើញនៅក្នុងគំនិតរបស់យើងការសម្រេចជោគជ័យដ៏ធំធេងរបស់យើង តែងតែនៅរង់ចាំនៅខាងមុខយើងជានិច្ច ។ នៅពេលដែលលោក ប៉ូល សរសេរសំបុត្រ គាត់បានសម្រេចជោគជ័យបានច្រើនរួចមកហើយចំពោះការងាររបស់ព្រះជាម្ចាស់ ដូចជាការបង្កើតព្រះវិហារ ការសរសេរបទគម្ពីរ ការប្រោសជម្ងឺ ការប្រឈមមុខជាមួយពួកខុសឆ្គង ការដេញអារក្ស ការហ្វឹកហ្វឺនដល់អ្នកឡើងកាន់តួនាទីជាបន្ត ។ មនុស្សជាច្រើន ដែលមានជីវប្រវត្តិបែបហ្នឹង អាចគិតថា គឺដល់ពេលត្រូវសម្រាក និង សប្បាយរីករាយ និង ជ័យជំនះរបស់ខ្លួន ។ ប៉ុន្តែសាវ័ក ប៉ូល បានពន្យល់យ៉ាងច្បាស់ពីគោលដៅនៃជីវិតរបស់គាត់ (៨-១១) និងទោះបីជាគ្រប់ទាំងអស់ ដែលគាត់បានធ្វើ គឺមិនបានសម្រេចបាននូវទិសដៅរបស់គាត់ ឬបានល្អឥតខ្ចោះនោះឡើយ(១២) ។ ដូច្នេះរឿងមួយ ដែលគាត់បានធ្វើ គឺគាត់បំភ្លេចចោលនូវអតីតកាល និង ខំព្យាយាមយ៉ាងខ្លាំងចំពោះអនាគត ។ ហើយគាត់បានប្រកាសដល់អ្នកទាំងអស់ដែលមានជំនឿមុតមាំឲ្យធ្វើដូចគ្នានោះដែរ ។

តើប៉ុន្មានដងទៅ ដែលប្រជារាស្ត្ររបស់ព្រះ ភ្លេចខ្លួនចំពោះការផ្តោតអារម្មណ៍ទៅអនាគត ហើយរស់នៅគិតតែពីរឿងអតីកាល ។ លោកឡុត បានរស់នៅយ៉ាងសុខស្រួលនៅក្នុងក្រុង សូដុម ប៉ុន្តែព្រះជាម្ចាស់មានផែនការថ្មី សម្រាប់គាត់ និង ទីក្រុងថ្មីសម្រាប់គាត់ ។ គាត់ត្រូវទេវតាទាញអូស ឲ្យគាត់ចេញពីកន្លែង ដែលគាត់រស់នៅដ៏សុខស្រួលកាលពីអតីតកាល ឲ្យទៅរស់នៅសម្រាប់ពេលអនាគត ។[១៦] ជនជាតិអ៊ីស្រា

---

[១៦] *លោកុប្បត្តិ(កំណើតពិភពលោក) ១៩:១២-២០, ២៦*

អែល នៅក្នុងវាលរហោស្ថាន ចង់វិលត្រឡប់ទៅកាន់ភាពទាសករវិញ នៅក្នុងប្រទេសអេស៊ីព្ទវិញ ជាជាងការទៅទទួលមរតកនៅក្នុងទឹកដីសន្យាថ្មី ។[១៧] ពួកជំនុំពួកជំនុំកាលមុនសម័យកិច្ចការ ១៥ គឺបានស្ថិតនៅក្នុងការរស់នៅក្នុងគ្រោះថ្នាក់មួយនៃការវិលត្រឡប់ទៅគោរពក្រិត្យវិន័យវិញ ។[១៨]

នៅក្នុងរបៀបដូចគ្នានេះដែរ បុគ្គលម្នាក់ៗ និង ពួកជំនុំសព្វថ្ងៃនេះជួនកាលផ្តេកផ្តួលទៅរកអតីតកាលច្រើនជាងគិតឆ្ពោះទៅរកអនាគត ។ នោះគឺជាផ្លូវដ៏ងាយស្រួលមួយ ។ អតីតកាលគឺ យើងធ្លាប់ស្គាល់ គឺវាមិនមែនប្លែក ហេតុដូច្នេះហើយគឺវាកក់ក្តៅស្រួល និង "មានសុវត្ថិភាព" ។ យើងអាចហាត់សមនឹងការទទួលជោគជ័យរបស់យើង និង យើងមិនខ្លាចមានការបរាជ័យណាមួយឡើយ ។ ប៉ុន្តែអតីតកាលគឺ ស្លាប់ និង មិនអាចប្តូរផ្លាស់បានឡើយ ជីវិតគឺនៅក្នុងពេលអនាគត ។ ហេតុអ្វីស្វែងរកមនុស្សរស់នៅក្នុងចំណោមមនុស្សស្លាប់? តាមពិតទៅការណែនាំឲ្យដឹងពីអនាគតបែបនេះ មិនមែនមានន័យថា យើងធីបចោលមេរៀនទាំងឡាយ ដែលយើងរៀនរួចមកហើយនោះទេ (១៦) ។

## ទីពីរ យើងរស់នៅសម្រាប់ថ្ងៃអនាគត មិនមែនសម្រាប់តែគ្រា បច្ចុប្បន្ននេះឡើយ (១៧-២១)

មនុស្សជាច្រើនរស់នៅ គឺរស់នៅសំរាប់តែពេលបច្ចុប្បន្ននេះឯងគឺសូម្បីតែគ្រីស្តបរិស័ទខ្លះក៏គិតដូច្នេះដែរ ។ ប៉ុន្តែបើរស់នៅបែបនោះមែនគឺរស់នៅជាខ្មាំងសត្រូវនៃឈើឆ្កាងរបស់ព្រះគ្រីស្តហើយ ។ គឺមនុស្ស

---

[១៧] *ជនគណនា(ជំរឿនប្រជាជន) ១១:៥, ១៨-២០; ១៤:១-៤; កិច្ចការ ៧:៣៩*

[១៨] *បញ្ហានេះក៏បានលើកឡើងមកនិយាយក្នុងពួកជំនុំ កាឡាទី និង ហេព្រើ ដែរ*

ទាំងនេះ គេយកក្រពះជាព្រះរបស់គេ គឺថាគេយកការស្រេកឃ្លានចង់ឆ្ងាញ់របស់គេ នៅក្នុងពេលបច្ចុប្បន្ននេះឯងធ្វើជាព្រះ ។ ចិត្តគំនិតរបស់គេ គឺផ្តោតលើពេលបច្ចុប្បន្ននេះ រឿងរ៉ាវនៃផែនដីគឺរបស់លោកិយនេះឯង ។ តែផ្ទុយទៅវិញ សិស្សពិតប្រាកដរស់នៅពេលបច្ចុប្បន្នមែនតែភ្នែកសម្លឹងឆ្ពោះទៅរកអនាគត ។ យើងជាពលរដ្ឋនៃនគរស្ថានសួគ៌យើងរង់ចាំព្រះអង្គសង្គ្រោះមកទីនោះឯង រូបកាយបច្ចុប្បន្នរបស់យើង និងសេចក្តីត្រេកត្រអាល គឺមិននៅស្ថិតស្ថេរបានឡើយ ។ យើងមិនត្រូវដើរជាន់ដានរបស់អេសាវឡើយ ដែលបានលះចោលនូវសិទ្ធិទទួលមរតកនៅថ្ងៃអនាគតរបស់ខ្លួនដោយសារតែសម្លមួយចាន ដែលស្កប់ចិត្តតែមួយភ្លែតនោះ។[១៩] តែសូមឲ្យយើងយកគំរូតាមលោក ម៉ូសេ យើងសុខចិត្តជ្រើសរើសឲ្យរាស្ត្ររបស់ព្រះជាម្ចាស់ មិនសូវសប្បាយចិត្ត ជាជាងការសប្បាយរីករាយក្នុងអំពើបាបគ្រាន់តែ មួយរយៈពេលខ្លី ពីព្រោះយើងសម្លឹងមើលទៅមុខចំពោះរង្វាន់ ដែលព្រះបំរុងទុកឲ្យ ។[២០] ដោយសារព្រះគ្រីស្តយើងសម្លឹងមើលទៅអំណារ នៅពីមុខយើង និង ទ្រាំទ្រនូវទុក្ខលំបាកនៅពេលបច្ចុប្បន្ននេះ ។[២១] ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន រួមទាំងការមិនគិតពីសេចក្តីរីករាយនៅពេលបច្ចុប្បន្ននេះ និង ការផ្តោតអារម្មណ៍ឆ្ពោះទៅអនាគតដ៏នៅអស់កល្ប របស់យើង ។

## ការមិនគិតពីប្រយោជន៍ផ្ទាល់ខ្លួន
## បញ្ជាក់ឲ្យឃើញដោយការអនុវត្តន៍ជាក់ស្តែង ៤:២-២៣

---

[១៩] *លោកុប្បត្តិ (កំណើតពិភពលោក) ២៥:២៩-៣៤; ហេព្រើ ១២:១៦*

[២០] *ហេព្រើ ១១:២៤-២៦*

[២១] *ហេព្រើ ១២:២*

ត្រង់ចំណុចនេះ បង្ហាញពីភាពមិនមែនអាត្មានិយម ដែលគ្រាន់តែទ្រឹស្តី ។ ចាប់ផ្តើមនៅជំពូក ៤:២ សំបុត្រនោះបង្ហាញពីគោលការណ៍អនុវត្តខ្លះៗ ដែលគំនិតអាត្មានិយមស្តែងចេញមក ។

## ជំបូងភាពមិនអាត្មានិយម គឺមានន័យថា ស្ម័គ្រព្រមធ្វើការជាមួយ អ្នកដទៃ (២-៣)

អ្នកបំរើព្រះល្អៗជួនកាលអាចបែងចែកបានតាមបញ្ហានៃអាត្មានិយមនេះឯង ។ ទាំងនាងអេវ៉ូឌី និងទាំងនាងស៊ុនទីក មាន"ការរីករាយស្តាប់ចិត្តដោយកាន់ខាងលោកប៉ូល ដោយមូលហេតុនៃដំណឹងល្អ ។" ឥឡូវនេះដោយការគោរពយ៉ាងកក់ក្តៅ និងមិនកាន់ជើងខាងណាៗ[២២] លោកប៉ូលជំរុញលើកទឹកចិត្តឲ្យមានការយល់ព្រម និង សហប្រតិបត្តិការរវាងអ្នកទាំងពីរ ។ តាមពិតទៅមានហេតុផលនៅក្នុងព្រះគម្ពីរនៃការចែកឲ្យដាច់រវាងគ្រីស្តបរិស័ទ ដែលប្រកាសថាជឿព្រះ តែគោលលទ្ធិគ្មានការគោរពកោតខ្លាចព្រះសោះ[២៣] និងការប្រព្រឹត្តិគ្មានការកោតខ្លាចព្រះសោះ[២៤] ។ ប៉ុន្តែបុគ្គលិកលក្ខណៈខុសៗគ្នា ក្នុងការខុសឆ្គងតិចតួច ដែលមានទុក្ខវេទនា[២៥] ដូចជាការយឺតយ៉ាវក្នុងការចំរើនលូតលាស់ក្នុងវ័យជាគ្រីស្តបរិស័ទ[២៦] និងជាសមាជិកភាពនៅក្នុងគណៈឬនិកាយផ្សេងៗ[២៧] ដែល

---

[២២] *ប្រើកិរិយាស័ព្ទដូចគ្នា ជាមួយគ្នា: "ខ្ញុំអង្វរជាមួយ* **Euodia** *និងខ្ញុំអង្វរជាមួយ* **Syntyche** *។*

[២៣] *ខ. យ៉ូហាន ៧-១១; រ៉ូម ១៦:១៧-១៨ ។*

[២៤] *ខ. ២ថែស្សាឡូនិក ៣:៦; ១កូរិនថូស ៥:៩-១១*

[២៥] *កូឡុស ៣:១២-១៣*

[២៦] *ម៉ាកុស ៨:១-២១*

[២៧] *ម៉ាកុស ៩:៣៨-៤១; ១កូរិនថូស ១:១០-១៣*

មិនមែនមាននៅក្នុងចំណោមនេះ ។ នៅពេល ដែលមានភាពចំរូងចំរាស់កើតឡើងដោយព្រោះហេតុផលមិនត្រឹមត្រូវ ជំនួយមកពីខាងក្រៅជួនកាលអាចទទួលយកនូវការផ្តល់ដំបូន្មាន ចំពោះ ការផ្សះផ្សាដ៏មានប្រសិទ្ធិភាព (៣) ។

## ទីពីរ ការមានភាពមិនអាត្មានិយមបញ្ជាក់ឲ្យឃើញ ការផ្តោតយក ចិត្តទុកដាក់ ចំពោះព្រះអម្ចាស់ (៤-៧)

លោក ប៉ូល លើកឡើងមក និយាយម្តងទៀត ពីខ្លឹមសារក្នុងជំពូក ៣:១-៣ ។ ការសម្លឹងឆ្ពោះទៅរកព្រះអម្ចាស់គឺមានន័យថាយើងនឹងសប្បាយរីករាយ ក្នុងព្រះអង្គមិនថាឡើយ យើងស្ថិតនៅក្នុងកាលៈទេសៈបែបណានោះឡើយ (៤) ។ គឺមានន័យថា យើងនឹងប្រព្រឹត្ត "ដោយសុភាព" ឬដោយប្រសើរឡើង "មិនធ្វើអ្វី ដែលរំលោភសិទ្ធិ"[២៨] អ្នកដទៃពីព្រោះយើងដឹងហើយថា ព្រះអម្ចាស់ទតរំពៃមើល និង ថ្ងៃណាមួយការត្រឹមត្រូវទាំងអស់អាចត្រឹមត្រូវក៏ថាបាននៅពេលនោះជិតមកដល់(៥)[២៩]។ លើសពីនោះទៅទៀតយើងអាចអធិស្ឋាន ដោយមានការទុកចិត្តជាជាងការព្រួយចិត្ត (៦-៧) ។

---

[២៨] *ពាក្យនេះ-និង **Cognates** "គឺប្រើសម្រាប់ការពិចារណា និង គិតគូរផ្នែកទំនាក់ទំនងជាផ្លូវការ ដែលប្រុងប្រៀបនឹងបន្ទាបបន្ថោយដល់សេចក្តីយុត្តិធម៌ដ៏តឹងរ៉ឹង ដែលមានច្បាប់ និង ការអះអាងរបស់សេចក្តីយុត្តិធម៌នោះឯង គឺផ្ទុយពីឥរិយាបថ ដែលទាមទារឲ្យមានសិទ្ធិ រួមទាំងសិទ្ធិផ្ទាល់ខ្លួន ដែលគេគិតថាគួរលើកស្ទួយ ទោះត្រូវចំណាយអ្វីក៏ដោយ" [**NIDNIT 2:** ២៥៦-៥៩ "ការបន្ទាបខ្លួន សុភាព ស្លូតបូត] " ហេតុដូច្នេះហើយ គំនិតដែលទាក់ទងនឹងភាពមិនអាត្មានិយម ត្រូវតែបញ្ជាក់ឲ្យបានច្បាស់ ។*

[២៩] *យ៉ាកុប ៥:១-៩; ១កូរិនថូស ៦:១-៨ ។*

## ទីបី ការមានភាពមិនអាត្មានិយម គឺបញ្ជាក់ឲ្យឃើញតាមការគិត និង រស់នៅក្នុងជីវិតបរិសុទ្ធ (៨-៩)

យើងនឹងគិតបរិសុទ្ធ (៨) និង រស់នៅបរិសុទ្ធ(៩)ជាជាងការគិតពីប្រយោជន៍ផ្ទាល់ខ្លួន ដោយគិតតែពីការអ្វីដែលមិនស្ថិតស្ថេរ និងសប្បាយរីករាយក្នុងការប្រព្រឹត្តិអំពើបាប ។

## ទីបួន ការមានភាពមិនអាត្មានិយម គឺសម្តែងចេញតាមរយៈនៃការស្កប់ចិត្ត (១០-១៤)

មនុស្សដែលគិតពីប្រយោជន៍ផ្ទាល់ខ្លួនចង់បានរហូតគឺមិនចេះស្កប់ឡើយ ។ អ្នកដែលមិនគិតពីអាត្មានិយម ដូចជាលោកប៉ូល "រៀន ស្កប់ចិត្ត ទោះជាស្ថិតនៅក្នុងកាលៈទេសៈណាក៏ដោយ"[៣០] ។ តាមការណែនាំឲ្យយើងបានដឹងថា ពួកសាវ័កដឹង "ថាខ្លួនមានច្រើនមិនខ្វះ" ដឹងពីរបៀបដែលរស់នៅក្នុងសភាពជាអ្នក "ទ័លក្រ" ។ ភាពទីទ័លក្រ គឺមិនមែនជាគុណប្រយោជន៍ ដែលនាំឲ្យយើងចង់ដាក់ខ្លួនជាជនក្រីក្រនោះឡើយ ដូចជាលោកសង្ឃ និង អ្នកគាំទ្ររបស់គេបានសន្មត់ចំពោះការនេះឯងរាប់សតវត្សរ៍មកហើយ ។ ក្តីអំណួតពីភាពទ័លក្រគឺមិនមែនតែជាមធ្យោបាយដ៏ល្អ ក្នុងការដកយកនូវសេចក្តីអំណួតចេញពីបុគ្គលណាម្នាក់ ។

---

*[៣០] គម្ពីរសញ្ញាថ្មី ជារឿយៗថែងពីសេចក្តីស្កប់ចិត្ត ទោះបីជាមានភាពទ័លក្រក៏ដោយ ។ ឧ. ហេព្រើ ១០:៣២-៣៤; ១៣:៥ ។ លូកា ៣:១៤; ៩:៥៨; ១ធីម៉ូថេ ៦:៥-៨ ។ គ្មានកន្លែងណាមួយ ដែលព្រះគម្ពីរមិនលើកទឹកចិត្តដល់ពួកអ្នកជឿឲ្យអះអាងយកសិទ្ធិទទួលសម្បត្តិទ្រព្យនៃនរកស្ថានសួគ៌នោះឡើយ ។*

## ទី ៥ ការមិនគិតពីភាពអាត្មានិយម គឺបង្ហាញឲ្យឃើញតាមរយៈថ្វាយតង្វាយ និង ការទទួលជំនួយ (១៥-២០)

ការដាក់ដង្វាយរបស់ ពួកជំនុំ ក្រុងភីលីព បានបង្ហាញយ៉ាងច្បាស់ពីភាពមិនអាត្មានិយម ប៉ុន្តែលោកប៉ូល ក៏ដូច្នេះដែរ ដែលបន្ទាបខ្លួនព្រមទទួលនូវការផ្គត់ផ្គង់ ដោយដួងចិត្តជ្រះថ្លា និង រីករាយចំពោះអំពើល្អដែលផ្តល់កិត្តិយសដល់អ្នកផ្តល់ជំនួយរបស់គាត់ ។

## សរុបសេចក្តី

ដូច្នេះនៅចុងបញ្ចប់នៃសំបុត្រដ៏ល្អបំផុតនៅក្នុងគម្ពីរសញ្ញាថ្មីអំណរ និង ការដឹងគុណដ៏ជ្រាលជ្រៅរបស់លោក ប៉ូល បានបង្ហាញយ៉ាងច្បាស់ និង ផុសចេញពីការសម្រេចចិត្តរបស់គាត់ មិនមែនដើម្បី ផ្តាប់ភ្នែករបស់គាត់ ឬ ផ្តាប់ភ្នែកអ្នកដទៃនោះឡើយ ។ តែផ្ទុយទៅវិញគាត់សម្លឹងឆ្ពោះទៅរកព្រះអម្ចាស់ និង រីករាយសាទរក្នុងព្រះអង្គ និង គិតដល់អ្នកដទៃ និង រកវិធីរបៀបណា ដែលគាត់អាចបំរើគេបានប្រសើរឡើង ។ ការដែលគាត់មិនគិតពីភាពអាត្មានិយមនោះឯងហើយ ដែលជា គន្លឹះនាំឲ្យគាត់មានអំណរ និង គាត់បបួលយើងឲ្យដើរតាមផ្លូវ ដែលគាត់កំពុងដើរ ។